# ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ

## លិខិតជ្រើសរើសមិនចូលរួមក្នុងការបញ្ចេញឈ្មោះនៅក្នុងបញ្ជីព័ត៌មាន

**២០១៣-២០១៤**

ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ អាចបញ្ចេញ "បញ្ជីព័ត៌មាន" តាមការកំណត់ដែលសមគួរ ដោយមិនចាំបាច់មានការយល់ព្រមជាលាយល័ក្ខអក្សរ លើកលែងតែលោកអ្នកបានជម្រាបក្រសួងអប់រំជាមុន តាមវិធីរបស់ក្រសួង ថាមិនឲ្យបញ្ចេញព័ត៌មាន។

បញ្ជីព័ត៌មាន រួមមាន៖ ឈ្មោះ អាស័យដ្ឋាន លេខទូរស័ព្ទ ថ្ងៃកំណើត និងស្រុកកំណើត មុខវិជ្ជាសិក្សា ការចូលរួមក្នុង សកម្មភាព និង កីឡាផ្សេងៗ ដែលគេបានទទួលស្គាល់ កំពស់/ទម្ងន់ បើសិនជាសមាជិកនៃក្រុមកីឡា វត្តមានអវត្តមាន សញ្ញាប័ត្រ រង្វាន់ រូបថត កាលវិភាគសិក្សា សាលាដែលធ្លាប់រៀន និងភាសាប្រើប្រចាំថ្ងៃ។

គោលបំណងសំខាន់នៃបញ្ជីព័ត៌មានគឺ ដើម្បីអនុញ្ញាតឲ្យ ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ យកព័ត៌មានទាំងនេះ ពីឯកសារសិក្សារបស់កូនលោកអ្នក ដាក់នៅក្នុងការបោះពុម្ពផ្សាយអ្វីមួយរបស់សាលា រួមមាន៖ កម្មវិធីសម្តែង រាយតួសម្តែងរបស់សិស្សក្នុងរឿងល្ខោន សារព័ត៌មានរបស់សាលា សៀវភៅប្រចាំឆ្នាំ បញ្ជីកិត្តិយស ឬនៅក្នុងបញ្ជីផ្សេងៗ ដែលគេទទួលស្គាល់ កម្មវិធីបញ្ចប់ការសិក្សា និងបញ្ជីសកម្មភាពកីឡាជាច្រើន ដូចជាកីឡាបាល់បោះ គេបង្ហាញពី ទម្ងន់និងកំពស់ របស់សមាជិកនៃក្រុមកីឡា។

ព័ត៌មាននេះក៏អាចផ្តល់ឲ្យទៅអង្គការនៅក្រៅក្រសួងណាដែលមានសិទ្ធិទទួលបាន បើសិនជាមានការស្នើសុំ។ អង្គការនៅក្រៅក្រសួងដែលមានសិទ្ធិទទួល រួមមាន តែគ្មានកំណត់ អង្គការ ផ្តល់អាហារូបករណ៍ សាលាវិជ្ជាជីវៈ/បច្ចេកទេស និងកន្លែងដែលសិស្សអាចធ្វើការ។ តាមការទទួលស្គាល់នូវសិទ្ធិរក្សាការសម្ងាត់របស់ក្រុមគ្រួសារ ច្បាប់របស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វៀ នឹងមិនផ្តល់បញ្ជីព័ត៌មាននេះទៅឲ្យ ក្រុមហ៊ុនឯកជនទេ។

មាតាបិតា ឬសិស្សានុសិស្សដែល (អាយុ១៨ឆ្នាំឡើងទៅ) មានសិទ្ធិមិនឲ្យគេបញ្ចេញបញ្ជីព័ត៌មាន ដោយមានការស្នើសុំជាលាយល័ក្ខអក្សរ។ បើសិនជាលោកអ្នកចង់បដិសេធមិនឲ្យគេបញ្ចេញបញ្ជីព័ត៌មាន ដោយមិនចាំបាច់មានការសរសេរយល់ព្រមជាមុន សូមបំពេញលិខិតនេះឲ្យបានពេញលេញ ហើយផ្ញើទៅសាលារបស់កូនលោកអ្នក ឲ្យទាន់ **ថ្ងៃទី២០ ខែធ្នូ ឆ្នាំ២០១៣**។ នៅពេលណាដែលលិខិតនេះបំពេញរួច ហើយផ្ញើទៅសាលា រួចហើយ ការជ្រើសរើសរបស់លោកអ្នកនឹងមិនអាចផ្លាស់ប្តូរបានទេ លុះត្រាតែលោកអ្នកបំពេញលិខិតថ្មី ហើយផ្ញើមកសាលាវិញ។ ប្រើលិខិតផ្សេងគ្នាសម្រាប់ក្មេងម្នាក់ៗ។ ***ផ្ញើលិខិតនេះត្រឡប់មកវិញ ក្នុងករណីដែលលោកអ្នកមិនចង់ឲ្យគេបញ្ចេញឈ្មោះនៅក្នុងបញ្ជីព័ត៌មាន។***

**ខ្ញុំមិនចង់**ឲ្យគេបញ្ចេញឈ្មោះនៅក្នុងបញ្ជីព័ត៌មានទេ ចំពោះករណីដូចខាងក្រោមនេះ៖

- ☐ កុំបញ្ចេញព័ត៌មានរបស់ខ្ញុំ នៅក្នុងបញ្ជីព័ត៌មានសិស្សឲ្យសោះ។ មិនឲ្យផ្តល់ព័ត៌មានសម្រាប់ ការបោះពុម្ពផ្សាយរបស់សាលា សកម្មភាពរបស់សាលា សាលាវិជ្ជាជីវៈ អង្គការផ្តល់អាហារូបករណ៍ ឬកន្លែងធ្វើការ។
- ☐ កុំបញ្ចេញព័ត៌មានរបស់ខ្ញុំ នៅក្នុងបញ្ជីព័ត៌មានសិស្ស លើកលែងតែសម្រាប់ ការបោះពុម្ពផ្សាយរបស់សាលា សកម្មភាពរបស់សាលា និងអង្គការនៅក្រៅក្រសួងដែលមានសិទ្ធិទទួល។
- ☐ កុំបញ្ចេញព័ត៌មានរបស់ខ្ញុំ នៅក្នុងបញ្ជីព័ត៌មានសិស្សឲ្យសោះ លើកលែងតែសម្រាប់ ការបោះពុម្ពផ្សាយ និង សកម្មភាពរបស់សាលា

| | | |
|---|---|---|
| *ឈ្មោះសិស្ស (សូមសរសេរឲ្យច្បាស់)* | *ឈ្មោះសាលា (សូមសរសេរឲ្យច្បាស់)* | *អត្តលេខសិស្ស* |
| | | |
| *ឈ្មោះ មាតាបិតា/អាណាព្យាបាល (សូមសរសេរឲ្យច្បាស់)* | *ហត្ថលេខារបស់ មាតាបិតា/អាណាព្យាបាល* | |
| | | |
| *ថ្ងៃខែ* | *ហត្ថលេខារបស់សិស្ស (បើសិនជាមានអាយុ១៨ឆ្នាំឡើងទៅ)* | |

ដើម្បីជ្រាបពីឯកសារដែលបានបកប្រែ និងព័ត៌មានបន្ថែមជាភាសាខ្មែរ សូមមើលក្នុងវិបសៃ៖ www.philasd.org/language/khmer